ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
អគ្គនាយកដ្ឋានយោធសេវា
នាយកដ្ឋានព័ត៌មាន
លេខ:..................

# សេចក្តីប្រកាសជូនដំណឹង

តបតាមការអញ្ជើញរបស់ក្រសួងការពារជាតិសហរដ្ឋអាមេរិក **ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** នៃព្រះរាជាណាចក្រកម្ពុជានឹងដឹកនាំគណៈ ប្រតិភូក្រសួងការពារជាតិមួយក្រុមចាកចេញដំណើរទៅកាន់សហរដ្ឋអាមេរិក នៅថ្ងៃពុធ ទី២៨ ខែកញ្ញា ដើម្បីចូលរួមក្នុងកិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន-សហរដ្ឋអាមេរិក ដែលនឹងប្រព្រឹត្តទៅ ចាប់ពីថ្ងៃទី២៩ ខែកញ្ញា ដល់ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៦ នៅរដ្ឋហាវ៉ៃ សហរដ្ឋអាមេរិក។

កិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិ អាស៊ាន-សហរដ្ឋអាមេរិក ជាឱកាសល្អមួយដើម្បីតាមដានកិច្ចពិភាក្សាប្រកបដោយផ្លែផ្កានៃកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូក(ADMM-Plus)ដែលបានរៀបចំឡើងកាលពីខែវិច្ឆិកា ឆ្នាំ២០១៥ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី និងកិច្ចពិភាក្សារបស់មេដឹកនាំនៅកិច្ចប្រជុំកំពូល អាស៊ាន-សហរដ្ឋអាមេរិក កាលពីខែកុម្ភៈ ឆ្នាំ២០១៦ នៅទីក្រុង Sunnylands រដ្ឋកាលីហ្វ័រ នីញ៉ា សហរដ្ឋអាមេរិក។

កិច្ចប្រជុំនេះក៏ជាផ្នែកមួយ នៃការបន្តយុទ្ធសាស្ត្រសហរដ្ឋអាមេរិកនូវការធ្វើឲ្យមានតុល្យភាពឡើងវិញចំពោះតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលក្រសួងការពារជាតិសហរដ្ឋអាមេរិកបន្តស្វែងរកឱកាសថ្មីៗ ដើម្បីគាំទ្រ និងភ្ជាប់ទំនាក់ទំនងជាមួយអាស៊ាន។

ក្រសួងការពារជាតិសហរដ្ឋអាមេរិកបានប្តេជ្ញាជួយកសាងសមត្ថភាពអាស៊ាន ដើម្បីពង្រឹងសន្តិភាព និងស្ថិរភាពក្នុងតំបន់ និងពង្រឹងកិច្ចសហប្រតិបត្តិការការពារជាតិពហុភាគី។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦

នាយកដ្ឋានព័ត៌មាន